The NGO Forum on Cambodia

FAIR FINANCE CAMBODIA
A MEMBER OF FAIR FINANCE ASIA

OXFAM

# ឯកសារគោលជំហរ របស់អង្គការសង្គមស៊ីវិល[1] សម្រាប់ប្រទេសកម្ពុជា និងអាស៊ាន ស្តីពីហិរញ្ញប្បទានបៃតង និងបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG)

**រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០២២**

ប្រទេសកម្ពុជា បានធ្វើការប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ តាមរយៈការខិតខំប្រឹងប្រែងក្នុងការសម្រេចឱ្យបាននូវក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជាឆ្នាំ២០១៨។ គោលការណ៍ហិរញ្ញប្បទានបៃតងប្រកបដោយចីរភាព មានភាពពាក់ព័ន្ធគ្នាយ៉ាងទូលំទូលាយ ក្នុងការធានាបាននូវការគ្រប់គ្រងបរិស្ថាន និងសង្គមប្រកបដោយប្រសិទ្ធភាព ដែលរួមចំណែកដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៧ ស្តីពីនិរន្តរភាពបរិស្ថាន។ នៅក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាជាពិសេសក្រសួងបរិស្ថាន បានចុះអនុស្សារណៈយោគយល់ជាមួយធនាគារជាតិនៃកម្ពុជា និងសមាគមធនាគារនៅកម្ពុជាស្តីអំពីគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពកម្ពុជា ឆ្នាំ ២០១៩ (CSFPs)[2] ដើម្បីជាមូលដ្ឋានសម្រាប់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ នៅក្នុងប្រទេសកម្ពុជាក្នុងការអភិវឌ្ឍនូវយុទ្ធសាស្ត្រចីរភាពហិរញ្ញវត្ថុរបស់ខ្លួន។ បន្ថែមពីលើនេះ នៅក្នុងសន្និសីទស្តីពីការប្រែប្រួលអាកាសធាតុរបស់អង្គការសហប្រជាជាតិ (COP26) រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តក្នុងការសម្រេចឱ្យបាននូវការកាត់បន្ថយការបញ្ចេញឧស្ម័នឱ្យបាន ៤២% នៅត្រឹមឆ្នាំ២០៣០ តាមរយៈការលើកកម្ពស់សកម្មភាពមួយចំនួនដែលអាចបញ្ចេញកាបូនទាប, ភាពធន់នឹងអាកាសធាតុ និងការរីកចម្រើនប្រកបដោយបរិយាបន្ន, និងការបង្កើនផ្ទៃដីព្រៃឈើសម្រាប់គម្រោង REDD+ ផងដែរ។

សម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌កម្ពុជា (FFC) វាយតម្លៃខ្ពស់នូវតួនាទីចម្បងរបស់វិស័យធនាគារ និងហិរញ្ញវត្ថុថា ជាយន្តការមួយក្នុងចំណោមយន្តការអនុវត្តន៍ជាច្រើនទៀត សម្រាប់ការសម្រេចបាននូវការរីកចម្រើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព និងការប្រតិបត្តិនូវហិរញ្ញប្បទានបៃតង។ នៅត្រឹមបំណាច់ឆមាសទី១ នៃឆ្នាំ២០២២ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលកំពុងមានវត្តមាននៅក្នុងប្រព័ន្ធធនាគារប្រទេសកម្ពុជារួមមាន ធនាគារពាណិជ្ជមានចំនួន ៥៨, ធនាគារឯកទេសមានចំនួន ៩, ការិយាល័យតំណាងចំនួន

[1] អង្គការសង្គមស៊ីវិលផ្សេងទៀតដែលបានចូលរួមនៅក្នុងសេចក្តីថ្លែងនេះ រួមមាន÷ អង្គការ DIAKONIA, វិទ្យាស្ថានចក្ខុវិស័យអាស៊ី (AVI), វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា (CDRI), និងសមាគមអភិរក្សសត្វព្រៃ (WCS)។

[2] សម្រាប់ព័ត៌មានបន្ថែម, សូមមើលតាមតំណភ្ជាប់នេះ https://www.abc.org.kh/CSFI/sustainable-finance-initiative

៦, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៥, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៨១, ក្រុមហ៊ុនផ្តល់កម្ចីហិរញ្ញវត្ថុចំនួន ១៧, គ្រឹះស្ថានផ្តល់សេវាទូទាត់ចំនួន ៣៣, គ្រឹះស្ថានផ្តល់ឥណទានជនបទចំនួន ២២៦, និងអ្នកប្តូរប្រាក់ចំនួន ២.៨៧៤នាក់។[3] ការឡើងនូវវត្តមានយ៉ាងច្រើននៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងនេះ គឺជាសក្ខីកម្មយ៉ាងច្បាស់អំពីការរីកចម្រើននូវសកម្មភាពសេដ្ឋកិច្ចជាច្រើនរួមបញ្ចូលទាំងការកើនឡើងនូវការវិនិយោគ និងគម្រោងអភិវឌ្ឍន៍នានាដែលស្នើឡើងតាមគោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា។ ជាការពិតណាស់ ការបំផ្លិចបំផ្លាញធនធានបរិស្ថាន និងសង្គមមានអន្តរទំនាក់ទំនងដោយផ្ទាល់និងប្រយោលជាមួយសកម្មភាពទាំងឡាយរបស់គម្រោងអភិវឌ្ឍន៍របស់រដ្ឋ និងវិស័យឯកជនដែលទទួលបានហិរញ្ញវត្ថុពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ជាមួយគ្នានេះដែរ ការខ្វះខាតនូវគោលនយោបាយនិងការអនុវត្តជាប្រព័ន្ធ និងជាប្រចាំអំពីបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) នៅក្នុងចំណោមគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទាំងឡាយបង្កឱ្យមាននូវហានិភ័យខ្ពស់នៅក្នុងការផ្តល់កម្ចីរបស់គ្រឹះស្ថានខ្លួនផ្ទាល់, ទៅលើសហគមន៍នានា, និងភពផែនដីទាំងមូល។ ការអង្កេតនិងការសិក្សាថ្មីដែលធ្វើឡើងដោយសម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌កម្ពុជា (FFC) និងអនុវត្តន៍ដោយវេទិកាការនៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ស្តីពីកាតព្វកិច្ចអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមនៅក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ និងគោលនយោបាយហិរញ្ញប្បទានបៃតងនៅក្នុងប្រទេសកម្ពុជា[4] បានលើកឡើងនូវតម្រូវការចាំបាច់មួយចំនួនក្នុងការដោះស្រាយជម្រើសគោលនយោបាយ និងការប្រតិបត្តិប្រកបដោយប្រសិទ្ធភាពអំពីហិរញ្ញប្បទានបៃតងនិងក្របខ័ណ្ឌESGសម្រាប់ធនាគារជាតិនៃកម្ពុជា, សមាគមធនាគារនៅកម្ពុជា, ក្រសួងបរិស្ថាន, គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ, និងបណ្តាភាគីពាក់ព័ន្ធជាច្រើនទៀត។ ជាក់ស្តែងក្រសួងបរិស្ថានត្រូវមានតួនាទីដឹកនាំដោយសហការជាមួយធនាគារជាតិនៃកម្ពុជា និងសមាគមធនាគារនៅកម្ពុជាក្នុងការព្រាងនូវការណែនាំ ឬគោលការណ៍បច្ចេកទេសអំពីកាតព្វកិច្ច និងការប្រតិបត្តិពាក់ព័ន្ធជាមួយ ESG សម្រាប់វិស័យធនាគារ និងហិរញ្ញវត្ថុដើម្បីសម្រេចឱ្យបាននូវទស្សនវិស័យហិរញ្ញប្បទានបៃតង ក្នុងរយៈពេលភ្លាមៗ និងយូរអង្វែង។

សេចក្តីថ្លែងខាងក្រោមនេះដែលលើកឡើងដោយសម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌កម្ពុជា (FFC) ស្នើសុំឱ្យមាននូវយុទ្ធសាស្ត្រ និងសកម្មភាពបន្ទាន់មួយចំនួនពីភាគីពាក់ព័ន្ធទាំងឡាយ ក្នុងការធានាឱ្យមាននូវការយកចិត្តទុកដាក់ និងការអន្តរាគមន៍ក្នុងរយៈពេលវែងសម្រាប់ហិរញ្ញប្បទានបៃតងប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកម្ពុជា÷

---

[3] ABC (2022). *Banking and Finance Newsletter in July-August 2022*. Association of Banks in Cambodia. Phnom Penh, Cambodia

[4] សម្រាប់របាយការណ៍ពេញលេញ, សូមទាញយកពី https://cambodia.fairfinanceasia.org/2022/04/08/research-on-environmental-and-social-impact-assessment-esia-compliance-in-cambodian-finance-and-banking/

សម្រាប់ប្រទេសកម្ពុជា÷

1. សម្រាប់ការបង្កើតនិងរៀបចំនូវគោលនយោបាយ ការណែនាំ និងក្របខ័ណ្ឌនានាដែលពាក់ព័ន្ធជាមួយនឹងហិរញ្ញប្បទានបៃតង និង ESG ជាការចាំបាច់ណាស់ក្នុងការកំណត់ឱ្យបានច្បាស់លាស់ និងជាក់លាក់អំពីនិយមន័យនិងការយល់ឃើញអំពីទស្សនាទាននៃហិរញ្ញប្បទានបៃតង និង ESG នៅក្នុងចំណោមភាគីពាក់ព័ន្ធទាំងឡាយ[5]។ ដោយផ្អែកទៅលើតួនាទីតាមគតិយុត្តក្នុងការកំណត់នូវអ្វីដែលជាហានិភ័យសង្គម និងបៃតង ក្រសួងបរិស្ថាន និងធនាគារជាតិនៃកម្ពុជាចាំបាច់ត្រូវដឹកនាំឈានមុខគេក្នុងការកំណត់នូវភាពច្បាស់លាស់ទៅលើភាពស្រពិចស្រពិលទាំងឡាយ ដែលពាក់ព័ន្ធជាមួយនឹងនិយមន័យទាំងអស់នោះ។ ការរៀបចំវត្តិករសាស្ត្រ (Taxonomy) សម្រាប់ប្រទេសកម្ពុជាជាឱកាសល្អក្នុងឆ្លើយតបទៅនឹងបញ្ហាទាំងអស់នេះ។

2. ស្របពេលដែលវត្តិករសាស្ត្រអាស៊ានសម្រាប់ហិរញ្ញវត្ថុប្រកបដោយចីរភាពត្រូវបានបង្កើតឡើង វាមានភាពចាំបាច់ណាស់សម្រាប់ប្រទេសកម្ពុជាក្នុងការផ្តួចផ្តើមឱ្យមាននូវវត្តិករសាស្ត្រ ស្រដៀងគ្នានេះដើម្បីបានជាទុនក្នុងការណែនាំក្នុងប្រទេសកម្ពុជា សំដៅសម្រួចសកម្មភាពទាំងឡាយដែលលើកស្ទួយនូវសកម្មភាពបម្លែងនៅក្នុងសេដ្ឋកិច្ចជាក់ស្តែងឱ្យមានការរីកចម្រើន និងឱ្យកាន់តែមាននិរន្តរភាព។ ក្រសួងបរិស្ថានគួរធ្វើការជិតស្និទ្ធជាមួយធនាគារជាតិនៃកម្ពុជាក្នុងការបង្កើត, ត្រួតពិនិត្យ, និងអនុម័តនូវវត្តិករសាស្ត្រកម្ពុជាសម្រាប់ហិរញ្ញវត្ថុប្រកបដោយចីរភាព ដើម្បីអនុវត្តន៍នូវគោលការណ៍ មិនបង្កទំនាស់ធ្ងន់ធ្ងរ, ការកាត់បន្ថយបម្រែបម្រួលអាកាសធាតុ, ផលប៉ះពាល់បរិស្ថាន, និងភពផែនដីប្រកបដោយសុខុមាលភាព។

3. ក្រសួងបរិស្ថាន ជាមួយនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គួរតែផ្តួចផ្តើម ឬបន្តការពិភាក្សាជាមួយធនាគារជាតិនៃកម្ពុជា និងសមាគមធនាគារនៅកម្ពុជា ដើម្បីកែសម្រួលដំណោះស្រាយក្នុងការបង្កើតគោលនយោបាយ រួមចំណែកដល់ការលើកកម្ពស់ការអនុវត្ត ESG ឬតម្រូវការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងកាតព្វកិច្ចអនុលោមផ្សេងៗសម្រាប់គ្រឹះស្ថានធនាគារនិង

[5] ឧទាហរណ៍មួយចំនួននៃការពិភាក្សាសំខាន់ៗដែលពាក់ព័ន្ធជាមួយនឹងវត្តិករសាស្ត្រអាស៊ាន, ហិរញ្ញវត្ថុបៃតង និងហិរញ្ញវត្ថុប្រកបដោយចីរភាពដែលត្រូវបានពិភាក្សានៅក្នុងចំណោមភាគីពាក់ព័ន្ធត្រូវបានបង្កើតឡើង ដូចជានៅក្នុងកំឡុងពេលនៃសន្និសីទស្តីពីស្ថាប័នធនាគារ និងហិរញ្ញវត្ថុនៅក្នុងខែសីហា ឆ្នាំ២០២២ ដែលរៀបចំឡើងដោយសមាគមធនាគារនៅកម្ពុជា។ https://abc.glueup.com/event/bank-and-financial-institutions-bfi-conference-57450/

ហិរញ្ញវត្ថុ និងសម្រាប់យុទ្ធសាស្ត្រហិរញ្ញប្បទានរបស់ពួកគេចំពោះគម្រោងអភិវឌ្ឍន៍[6]។ ដោយផ្អែកលើអនុស្សារណៈយោគយល់ក្នុងឆ្នាំ២០១៩ គោលនយោបាយរួមមួយដែលជាឧទាហរណ៍នៃការអនុវត្តអនុស្សរណៈនេះ គួរតែជា *"សេចក្ដីប្រកាសរួមស្ដីពីតម្រូវការនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ឬការអនុលោមលើការប្រតិបត្តិ ESG សម្រាប់វិស័យធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជា"*។

4. ផ្អែកលើស្មារតីនៃអនុស្សារណៈយោគយល់ឆ្នាំ២០១៩ ស្ដីពីគំនិតផ្ដួចផ្ដើមហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា[7] ក្រសួងបរិស្ថាន ធនាគារជាតិនៃកម្ពុជា និងសមាគមធនាគារនៅកម្ពុជា គួរតែបង្កើតផែនការសកម្មភាពរួមដ៏លម្អិត និងជាក់លាក់មួយបន្ថែមទៀត និងកំណត់ព្រឹត្តិការណ៍ឬគោលដៅសំខាន់ៗច្បាស់លាស់ ដើម្បីណែនាំដល់ការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម (ESIA) និង ESG ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ដោយផ្ដោតលើការផ្ដល់ហិរញ្ញប្បទានបៃតង និងការដាក់បញ្ចូលនូវការប្រតិបត្តិ ESIA/ESG ជាសកម្មភាពស្ថាប័នទៅក្នុងប្រតិបត្តិការសេវាកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងឡាយ ក៏ដូចជាកាតព្វកិច្ចរបស់អតិថិជនដូចគ្នាផងដែរ។

5. ដើម្បីជាចំណុចចាប់ផ្ដើម និងដើម្បីសម្រួលការងារ, ធនាគារជាតិនៃកម្ពុជាត្រូវដាក់ចេញនូវគោលនយោបាយណែនាំមួយ (កំណត់ជាកាតព្វកិច្ច) ដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងឡាយ ដើម្បីអនុវត្ត ESIA/ESG ជាពិសេសគឺអនុក្រឹត្យលេខ ៧២, សេចក្ដីប្រកាសលេខ ០២១, ០៩២, ១១៦, ១១៨, ១១៩, ១២០ និង ៣៧៦[8] និងបទប្បញ្ញត្តិ ESG ពាក់ព័ន្ធផ្សេងទៀត មុនពេលផ្ដល់

---

[6] បញ្ជីគម្រោងអភិវឌ្ឍន៍ជាក់លាក់មាននៅក្នុងបញ្ជីឧបសម្ព័ន្ធនៃសេចក្ដីប្រកាសលេខ ០២ ប្រ.ប.ក ប.ស.ទ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍នានា។ សេចក្ដីប្រកាសនេះអាចទាញយកបានពី https://data.opendevelopmentcambodia.net/laws_record/prakas-no-021-on-the-classification-of-environmental-impact-assessment-for-development-projects.
The list of specific development projects exists in the Appendix List of Declaration no. 021 PRK.BST dated 03 February 2020 on the classification of environmental impact assessment for development projects. The

[7] សម្រាប់ព័ត៌មានបន្ថែម, សូមមើល https://www.abc.org.kh/CSFI/about-csfi. អនុស្សារណៈយោគយល់បានកំណត់ការប្ដេជ្ញាចិត្តមួយចំនួនឧទាហរណ៍ (១) កិច្ចសហការ និងជំនួយទៅវិញទៅមកដើម្បីកសាងសមត្ថភាព និងលើកកម្ពស់ការយល់ដឹងក្នុងចំណោមមន្ត្រីបុគ្គលិក និងបុគ្គលដែលពាក់ព័ន្ធនឹងការអនុវត្តហិរញ្ញវត្ថុប្រកបដោយចីរភាព។ (២) ចែករំលែកព័ត៌មាន និងឯកសារទាក់ទងនឹងការអនុវត្តហិរញ្ញវត្ថុប្រកបដោយចីរភាព។ (៣) សហការរៀបចំកម្មវិធីដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាព។(៤) កិច្ចសហការ និងជំនួយបច្ចេកទេសក្នុងការអភិវឌ្ឍ និងអនុវត្តគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាព។ និង (៥) ផ្ដល់កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលជាមួយអង្គការ ឬស្ថាប័នពាក់ព័ន្ធដើម្បីអភិវឌ្ឍន៍ និងអនុវត្តគោលនយោបាយហិរញ្ញវត្ថុប្រកបដោយចីរភាព។

[8] គតិយុត្តិទាំងនេះអាចទាញយកតាមតំណភ្ជាប់នេះ https://bit.ly/3AGQxVB

ប្រាក់កម្ចី ឬការអនុម័តឥណទានរបស់ពួកគេ។ លើសពីនេះ របាយការណ៍អនុលោមភាពចំពោះគោលនយោបាយ និងបទប្បញ្ញត្តិទាំងនេះត្រូវដាក់ជូនធនាគារជាតិនៃកម្ពុជា និងក្រសួងបរិស្ថាន ដើម្បីទុកជាឯកសារ និងឯកសារយោង និងសម្រាប់ធ្វើសវនកម្មលើការអនុវត្តការងាររបស់ពួកគេនៅពេលក្រោយ។

6. ក្រោមជំនួយផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីដៃគូរដែលចាប់អារម្មណ៍ ក្រសួងបរិស្ថានជាមួយនឹងនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គួរបង្កើតគោលការណ៍ណែនាំបន្ថែមអំពីនីតិវិធី និងស្តង់ដាប្រតិបត្តិអំពី ESIA/ESG ដែលអាចអនុវត្តបានជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។ នីតិវិធី និងស្តង់ដានេះរួមមានសេចក្តីប្រកាសរួម (រវាងក្រសួងបរិស្ថាននិងធនាគារជាតិនៃកម្ពុជា) ស្តីពីតម្រូវការសម្រាប់ការអនុលោមតាម ESIA/ESG ក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ និងសៀវភៅណែនាំស្តីពីច្បាប់និងបញ្ញត្តិទាក់ទងនឹង ESIA/ESG និងនីតិវិធីសម្រាប់ការត្រួតពិនិត្យ និងអនុម័តរបាយការណ៍ ESIA/ESG, ដំណើរការនៃការចូលរួមជាសាធារណៈនៅក្នុងការប្រតិបត្តិ ESIA/ESG, ការអង្កេតតាមដានបរិស្ថាន, និងបែបបទរដ្ឋបាលមួយចំនួន (ឧ. តារាងសម្រាប់ការវាយតម្លៃរហ័ស ក្នុងការចាត់ថ្នាក់ហានិភ័យបរិស្ថានលើផលប័ត្រប្រាក់កម្ចីជាដើម) ដែលអាចជួយសម្រួលដល់ការប្រតិបត្តិរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការអនុវត្តតម្រូវការ ESIA/ESG នៅលើប្រាក់កម្ចីសម្រាប់អតិថិជន។

7. គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជាគួរតែគិតឡើងវិញនូវតួនាទីរបស់ពួកគេក្នុងការគាំទ្រដល់ការសម្រេចបាននូវសមិទ្ធផលនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព របស់ប្រទេសកម្ពុជា (CSDGs) តាមរយៈការប្រតិបត្តិតាមគោលនយោបាយ និងការប្តេជ្ញាចិត្តរបស់ពួកគេចំពោះការអនុវត្ត ESIA/ESG ។ ស្ថាប័នទាំងនេះអាចរៀបចំការអនុវត្តក្នុងស្ថាប័នរបស់ពួកគេដោយយកគម្រូតាមគោលការណ៍ក៏ដូចជាការប្រតិបត្តិ ESIA/ESG មួយចំនួននៅក្នុងតំបន់ និងសកលលោក ឧទាហរណ៍ គោលការណ៍អេក្វាទ័រ, វត្តិករសាស្ត្រអាស៊ានសម្រាប់ហិរញ្ញវត្ថុប្រកបដោយចីរភាព[9], និងមគ្គុទ្ទេសស្តីពីវិធីសាស្ត្រអន្តរជាតិសម្រាប់ហិរញ្ញវត្ថុយុត្តិធម៌ (FFGI)[10] ដើម្បីបង្កើតគោលនយោបាយឱ្យកាន់តែច្បាស់អំពីគោលការណ៍ និងការអនុវត្ត ESIA/ESG។

8. គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបន្តពង្រឹងនិងដំណើរការប្រតិបត្តិការផ្ទៃក្នុង និងប្រាក់កម្ចីរបស់ពួកគេលើការអនុវត្ត ESIA/ESG ឱ្យបានហ្មត់ចត់បន្ថែមទៀត មុនពេលអនុម័តប្រាក់កម្ចី ដោយ

---

[9] https://asean.org/wp-content/uploads/2021/11/ASEAN-Taxonomy.pdf

[10] សម្រាប់ការណែនាំលម្អិត, សូមមើលតាមតំណភ្ជាប់នេះ https://fairfinanceguide.org/ff-international/about-us/#panel-2.

សង្កត់ធ្ងន់លើនីតិវិធីសម្រាប់ការវាយតម្លៃនិងគ្រប់គ្រងប្រាក់កម្ចី និងការត្រួតពិនិត្យប្រតិបត្តិការប្រាក់កម្ចីនៅដំណាក់កាលបន្តបន្ទាប់។ ក្នុងករណីដែលប្រាក់កម្ចីមិនត្រូវបានប្រើសម្រាប់គោលបំណងត្រឹមត្រូវ ឬប្រើប្រាស់ដាច់ដោយឡែកពីគ្នាក្នុងប្រភេទអាជីវកម្មដែលហាមឃាត់ដោយច្បាប់រដ្ឋ ឬងាកចេញពីគោលនយោបាយកម្ចីរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬប្រើប្រាស់សម្រាប់សកម្មភាពណាមួយដែលអាចបង្កហានិភ័យដល់បរិស្ថាន និងសង្គម នោះកម្ចីនោះត្រូវតែផ្អាក ឬដកចេញភ្លាមៗ ឬអ្នកខ្ចីត្រូវបានតម្រូវឱ្យធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម (ESIA) ឬបង្ហាញនូវការប្តេជ្ញាចិត្តលើការអនុវត្ត ESG ឬត្រូវបំពេញកាតព្វកិច្ចផ្លូវច្បាប់របស់ក្រសួងពាក់ព័ន្ធណាមួយ មុនពេលនៃការបញ្ចេញប្រាក់កម្ចី ឬអាចបន្តកម្ចីបានឡើងវិញ។ ក្នុងករណីធ្ងន់ធ្ងរ ប្រាក់កម្ចីត្រូវបញ្ចប់ដោយគ្មានលក្ខខណ្ឌ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវតែធ្វើការវាយតម្លៃហានិភ័យដោយផ្អែកលើ ESIA/ESG តាមកាលកំណត់ជាក់លាក់ណាមួយដើម្បីពិនិត្យមើលថាតើគម្រោងទាំងនោះ នៅតែអនុលោមតាមគោលការណ៍ណែនាំនៃការផ្តល់ប្រាក់កម្ចីរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែរឬយ៉ាងណា។

9. សម្រាប់ចក្ខុវិស័យរយៈពេលវែង និងតាមស្មារតីនៃអនុស្សារណៈយោគយល់នៅខែ កញ្ញា ឆ្នាំ ២០១៩ ក្រសួងបរិស្ថាន, ធនាគារជាតិនៃកម្ពុជា, និងសមាគមធនាគារនៅកម្ពុជា គួរតែរួមគ្នាបង្កើតផែនការយុទ្ធសាស្ត្ររួមមួយសម្រាប់ការអប់រំ ផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹង និងចំណេះដឹងអំពីគោលការណ៍ ESIA/ESG ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជា។ ផែនការនេះត្រូវមានគោលបំណងបង្កើនការយល់ដឹងរបស់សាធារណជនទូទៅ, គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ, និងសហគមន៍មូលដ្ឋានជាទូទៅ។[11]

10. ជាមួយគ្នានេះផងដែរ រាជរដ្ឋាភិបាលកម្ពុជាគួរពិចារណាលើការបង្កើត និងបង្កើនគ្រឹះស្ថានហិរញ្ញវត្ថុរបស់រដ្ឋ រួមមានធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម, ធនាគារសម្រាប់សហគ្រាសធុនតូចនិងមធ្យម និងជំរុញគាំទ្រដល់គ្រឹះស្ថានហិរញ្ញវត្ថុឯកជនផ្សេងទៀត ដើម្បីបង្កើនគម្រោងហិរញ្ញប្បទានបៃតងរបស់ពួកគេ។ លើសពីនេះ រាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់លើវិស័យជាក់លាក់ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ជាឧទាហរណ៍ ការលើកកម្ពស់ការអនុវត្តកម្មវិធីធានារ៉ាប់រងដំណាំ និងការប្រើប្រាស់និងផលិតកម្មប្រកបដោយនិរន្តរភាព តាមរយៈភាពជាដៃគូសាធារណៈ និងឯកជន

[11] ផែនការគួរតែលើកឡើងពីបញ្ហាសំខាន់ៗដូចជា (ក) តើអ្វីជា ESIA/ESG? (ខ) ដំណើរការវាយតម្លៃ ត្រួតពិនិត្យនិងអនុម័តESIA នៅកម្ពុជា (គ) ក្របខ័ណ្ឌច្បាប់ក្នុងវិស័យបរិស្ថាន និងធនាគារ និងហិរញ្ញវត្ថុ និង ESG (ឃ) តួនាទីសំខាន់របស់ក្រសួងធនធានទឹក និងឧតុនិយម ធនាគារជាតិនៃកម្ពុជា និងម្ចាស់គម្រោង។ និង (ង) អត្ថប្រយោជន៍នៃការអនុវត្តកាតព្វកិច្ចលើ ESIA/ESG ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។

និងការបង្កើនការវិនិយោគលើថាមពលកកើតឡើងវិញ, អាជីវកម្មកសិ-ពាណិជ្ជកម្មនិងដំណាំធន់នឹងអាកាសធាតុ, កសិកម្មឆ្លាតវៃទប់ទល់អាកាសធាតុ, និងកសិកម្មប្រកបដោយនិរន្តរភាពជាដើម។

11. សម្រាប់គោលបំណងនៃកិច្ចគាំពារបរិស្ថាន និងសង្គមរយៈពេលវែង ក្រសួងបរិស្ថាន និងធនាគារជាតិនៃកម្ពុជា គួរតែផ្តល់ការណែនាំបច្ចេកទេសតាមរយៈគោលនយោបាយ និងឧបករណ៍អនុវត្តមួយចំនួន (ដូចជាគោលការណ៍ណែនាំបច្ចេកទេសពាក់ព័ន្ធ) ដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលផ្តល់ប្រាក់កម្ចី ដោយតម្រូវឱ្យគ្រឹះស្ថានផ្តល់ប្រាក់កម្ចីទាំងនោះ បង្កើតនូវប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) សម្រាប់ស្ថាប័នរបស់ខ្លួនដើម្បីធានាថាបញ្ហាបរិស្ថាន សង្គម ឬហានិភ័យដែលអាចបណ្តាលមកពីការប្រើប្រាស់ប្រាក់កម្ចីធនាគារ និងប្រតិបត្តិការធនាគារនឹងត្រូវបានជៀសវាង, កាត់បន្ថយ, ឬផ្តល់សំណងសម្រាប់ការខូចខាតដែលមិនអាចស្តារឡើងវិញបាន។

12. ជាឧទាហរណ៍ និយតករដូចជាក្រសួងបរិស្ថាន និងធនាគារជាតិនៃកម្ពុជាគួរតែគិតគូរអំពីយន្តការលើកទឹកចិត្តសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងឡាយណាដែលជាម្ចាស់ជើងឯកទាំងស្រុងលើការប្រតិបត្តិតាមគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពកម្ពុជា (CSFP) ដើម្បីលើកទឹកចិត្តពួកគេឱ្យជំរុញការអនុវត្តកាន់ប្រសើរឡើង និងធ្វើជាគំរូសម្រាប់ការគ្រាប់តាមផ្សេងៗទៀត។ ឧទាហរណ៍មួយអាចជាការលើកលែងទាក់ទងនឹងពន្ធ ឬការវាយតម្លៃនិងលើកសរសើរប្រចាំឆ្នាំសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទាំងឡាយណា ដែលឆ្លងកាត់ការវាយតម្លៃការអនុវត្តយ៉ាងហ្មត់ចត់ ដោយប្រៀបធៀបជាមួយនឹងសូចនាករហិរញ្ញប្បទានបៃតងដោយក្រសួងបរិស្ថាន និងធនាគារជាតិនៃកម្ពុជា ។ ពេលខ្លះ ការអនុវត្តល្អក្នុងរយៈពេលខ្លីត្រូវទទួលបានរង្វាន់ និងផ្សព្វផ្សាយជាសាធារណៈ។ ម្យ៉ាងវិញទៀត វាជាការប្រសើរក្នុងការជៀសវាងនូវការលើកទឹកចិត្តដោយមិនទាន់បានសាកល្បងលើមូលដ្ឋាននៃការអនុវត្តក្នុងរយៈពេលវែងសម្រាប់និរន្តរភាព។

13. សម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌កម្ពុជា (FFC) ស្នើសុំរាជរដ្ឋាភិបាលកម្ពុជា ក្នុងនាមជាប្រធានអាស៊ានដើម្បីលើកទឹកចិត្តដល់រដ្ឋជាសមាជិកអាស៊ាន (AMS) ឱ្យអនុម័ត និងបង្កើតនូវក្របខ័ណ្ឌរួមស្តីពីការផ្តល់ហិរញ្ញប្បទានបៃតង ឬគំនិតផ្តួចផ្តើមហិរញ្ញប្បទានបៃតងប្រកបដោយចីរភាព និងជាពិសេសការអនុលោមតាមការប្រតិបត្តិ ESIA/ESG ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។ ជាងនេះទៅទៀត ដោយសារភាពជាប្រធានអាស៊ាននៃប្រទេសកម្ពុជានឹងត្រូវបញ្ចប់ត្រឹមឆ្នាំ២០២២ សម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌កម្ពុជា (FFC) ស្នើសុំរាជរដ្ឋាភិបាលកម្ពុជាប្រគល់និងផ្ទេរគោលនយោបាយ

ហិរញ្ញប្បទានបៃតង និងការប្តេជ្ញាចិត្តពាក់ព័ន្ធទាំងនេះទៅដល់ប្រទេសឥណ្ឌូនេស៊ីសម្រាប់ការពិភាក្សា និងការចូលរួមជាបន្តក្នុងនាមជាប្រធានអាស៊ានរបស់ពួកគេនៅឆ្នាំ២០២៣។

សម្រាប់អាស៊ាន

1. គួរតែមានស្តង់ដារួមមួយអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមឆ្លងដែនសម្រាប់ក្របខ័ណ្ឌអាស៊ាន ដើម្បីធានាថាគម្រោងរដ្ឋអន្តរសមាជិកគឺត្រូវបានរួមបញ្ចូល និងត្រូវបានអនុលោមជាកាតព្វកិច្ចក្នុងការអនុវត្តន៍ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដែលមានសណ្ឋានរួមគ្នា។ ជាឧទាហរណ៍ ផ្លូវអាស៊ានរត់កាត់ប្រទេសជាច្រើន ប៉ុន្តែការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមត្រូវបានអនុវត្តជាលក្ខណៈឯកតោក្នុងប្រទេសនីមួយៗ ហើយមិនអាចសម្របសម្រួលបានទេដើម្បីឱ្យមានទិដ្ឋភាពរួមទូទៅក្នុងតំបន់អំពីហេតុ និងផលប៉ះពាល់ និងកិច្ចសហការគ្នាដើម្បីជម្នះនូវផលវិបាកនានា។ សម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌កម្ពុជា (FFC) ស្នើសុំអាស៊ានក្នុងការរៀបចំនូវគោលការណ៍ណែនាំ និងពិធីសារទូទៅលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមសម្រាប់រដ្ឋសមាជិកអាស៊ាន (AMS) ដោយពិនិត្យលើគោលនយោបាយ ពិធីការ និងក្របខ័ណ្ឌរបស់ប្រទេសនីមួយៗ និងបង្កើតសេចក្តីព្រាងសម្រាប់ការពិគ្រោះយោបល់ចុងក្រោយ។

2. វត្ថិករសាស្រ្តអាស៊ានសម្រាប់ហិរញ្ញវត្ថុប្រកបដោយចីរភាពត្រូវបានបង្កើតឡើង និងអនុម័តដូចដែលបានបំផុសគំនិតដោយកិច្ចប្រជុំរបស់រដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន និងអភិបាលធនាគារកណ្តាល (AFMGM) ក្នុងឆ្នាំ២០១៩។ រដ្ឋសមាជិកអាស៊ាន (AMS) រួមទាំងកម្ពុជានឹងប្តេជ្ញាបន្ថែមទៀតក្នុងការធ្វើជាតួបនីយកម្មនូវវត្ថិករសាស្រ្តដោយមានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធសំខាន់ៗ រួមទាំងវិស័យឯកជន ដើម្បីសម្រាប់ជាផលប្រយោជន៍បរិស្ថាន និងសុខុមាលភាពសង្គមរបស់ខ្លួន។

3. ក្រុមប្រឹក្សាភិបាលវត្ថិករសាស្រ្តអាស៊ាន (ATB) និងលេខាធិការដ្ឋានអាស៊ានត្រូវបង្កើតផែនការការងារជាយុទ្ធសាស្រ្តសម្រាប់ការកសាងសមត្ថភាព និងការចែករំលែកចំណេះដឹងក្នុងចំណោមស្ថាប័នហិរញ្ញវត្ថុរបស់រដ្ឋសមាជិកអាស៊ាន (AMS) ស្តីពីហិរញ្ញវត្ថុប្រកបដោយចីរភាព, ការគ្រប់គ្រងហានិភ័យលើ ESG, ការបើកបង្ហាញអំពីហានិភ័យអាកាសធាតុ។ល។ ដល់មន្ត្រីធនាគារ និងស្ថាប័នបរិស្ថានផ្សេងៗទៀត។

ក្រុមប្រឹក្សាភិបាលវត្តិករសាស្រ្តអាស៊ាន (ATB) ត្រូវធានាថាមានយន្តការបណ្តឹងតវ៉ា និងដំណោះស្រាយដ៏រឹងមាំមួយដែលរៀបចំដោយរដ្ឋាភិបាល និងដែលអាចដំណើរការបាន និងត្រូវធានាថាលំហរសម្រាប់ការសន្ទនាគ្នាទៅវិញទៅមកជាមួយសហគមន៍និងអង្គការសង្គមស៊ីវិលលើវិធានការគោលនយោបាយផ្សេងៗ ជាពិសេសសម្រាប់ការផ្តល់ធាតុចូលដល់សេចក្តីព្រាងបន្ទាប់នៃវត្តិករសាស្រ្តអាស៊ាន។

## អំពីសម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌កម្ពុជា (FFC)

សម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌កម្ពុជា (FFC) ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៩ និងដែលមានអង្គការសង្គមស៊ីវិលចំនួនប្រាំ (អុិកស្វាម, វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា, គណៈកម្មការសហប្រតិបត្តិការដើម្បីកម្ពុជា, អង្គការតម្លាភាពកម្ពុជា និងអង្គការ ActionAid កម្ពុជា), និងអង្គការសីលការ និងទីភ្នាក់ងារអង្គការសហប្រជាជាតិជាអ្នកសង្កេតការណ៍។ សម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌កម្ពុជា (FFC) មានគោលបំណងចូលរួមចំណែក កាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការវិនិយោគឆ្លងដែនលើសិទ្ធិមនុស្ស បរិស្ថាន និងការប្រែប្រួលអាកាសធាតុ ជាពិសេសស្ថាប័នហិរញ្ញវត្ថុចម្រុះជាតិសាសន៍ ធនាគារ និងក្រុមហ៊ុនធានារ៉ាប់រង និងដើម្បីបង្កើនការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន។ សម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌កម្ពុជា (FFC) មានប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ដែលនៅក្នុងនោះសម្ព័ន្ធអង្គការសង្គមស៊ីវិលដឹកនាំការស្រាវជ្រាវ និងការចូលរួមជាមួយភាគីពាក់ព័ន្ធសំខាន់ៗ រួមមានស្ថាប័ននិយតកម្មហិរញ្ញវត្ថុ និងគោលនយោបាយ, សមាគមធនាគារនិងវិនិយោគ, ធនាគារអភិវឌ្ឍន៍ពហុភាគី និងស្ថាប័នសិក្សាធិការនានា។ សម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌កម្ពុជា (FFC) គឺជាសមាជិកនៃសម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌អាស៊ី (Fair Finance Asia) ដែលជាបណ្តាញក្នុងតំបន់នៃអង្គការសង្គមស៊ីវិល ដែលប្តេជ្ញាធានាថាការសម្រេចចិត្តផ្តល់ហិរញ្ញប្បទានរបស់ស្ថាប័នហិរញ្ញវត្ថុនៅក្នុងតំបន់គោរពដល់សុខុមាលភាពសង្គម និងបរិស្ថានរបស់សហគមន៍មូលដ្ឋាន។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

១. លោក ភួន យូ អ្នកសម្របសម្រួលសារព័ត៌មាន និងទំនាក់ទំនង

yu@ngoforum.org.kh | 017 575 808

២. លោកស្រី កេក ណារ៉ាទេវី អ្នកសម្របសម្រួលទំនាក់ទំនងនៃអង្គការអុកស្វាម

Naratevy.Kek@oxfam.org | 012 847 412